**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ១១៥....សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
# ស្តីពី
# ការនាំចេញធនិទាញបណ្តោះអាសន្ន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

រដ្ឋបាលគយអាចអនុញ្ញាតឲ្យធ្វើការនាំចេញបណ្តោះអាសន្ននូវទំនិញពីដែនគយ ស្រប តាមបញ្ញត្តិមាត្រា ១៧ នៃច្បាប់ស្តីពីគយ ដើម្បីគោលបំណងដូចតទៅ៖

ក- ធ្វើការជួសជុល បំប្លែង ទទួលពលកម្មបន្ថែម ឬស្វាគារបន្ថែមផ្សេងៗ

ខ- សម្រាប់តាំងពិពណ៌ ឬផ្សព្វផ្សាយពាណិជ្ជកម្ម។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

គ- ធ្វើប្រតិបត្តិការ ឬប្រើប្រាស់នៅក្រៅដែនគយ ហើយបន្ទាប់មកនាំចូលមកវិញ ដោយរាប់ទាំងទំនិញប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ ។

ឃ- សម្រាប់គោលបំណងផ្សេងទៀត តាមការសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ២.-**

អ្នកនាំចេញ ឬអ្នកតំណាងដែលបានទទួលសិទ្ធិ ត្រូវដាក់ជូនរដ្ឋបាលគយនូវប្រតិវេទន៍គយនាំចេញ ដោយបញ្ជាក់ថាទំនិញនោះត្រូវនាំចេញបណ្ដោះអាសន្ន ។

**ប្រការ ៣.-**

ទំនិញនាំចេញបណ្ដោះអាសន្នមិនត្រូវជាប់ពន្ធ និងអាករឡើយ ។

នៅពេលនាំចូលមកវិញ ពន្ធ និងអាករត្រូវបង់តែលើមូលដ្ឋានតម្លៃបន្ទុកចំណាយឯបរទេសនៃការជួសជុល បំប្លែង ឬពលកម្មបន្ថែមលើទំនិញដែលបាននាំចេញបណ្ដោះអាសន្ននោះ និងបន្ទុកតម្លៃផ្សេងទៀតដែលត្រូវជាប់ពន្ធ និងអាករ ។

**ប្រការ ៤.-**

ទំនិញនាំចេញបណ្ដោះអាសន្នដែលស្ថិតនៅក្នុងរយៈពេលនៃការធានា ហើយដែលពុំមានការទូទាត់តម្លៃនៃការជួសជុល ត្រូវទទួលបានការលើកលែងពន្ធ និងអាករនៅពេលនាំចូលមកវិញ ។ ប្រតិវេទករត្រូវបង្ហាញនូវសម្គាល់គ្រប់គ្រាន់ដល់មន្ត្រីគយមានសមត្ថកិច្ចថា ការជួសជុលនោះធ្វើឡើងនៅក្នុងកំឡុងពេលនៃការធានា ។

**ប្រការ ៥.-**

មុនពេលអនុញ្ញាតឲ្យនាំចេញបណ្ដោះអាសន្ន មន្ត្រីគយមានសមត្ថកិច្ចអាចតម្រូវឲ្យផ្ដល់នូវសម្គាល់ដែលបង្ហាញថាទំនិញនោះត្រូវបានផលិតនៅកម្ពុជា ឬប្រសិនបើជាទំនិញនាំចូល ត្រូវបង្ហាញថាទំនិញនោះបាននាំចូលដោយស្របច្បាប់ ហើយបានបង់ពន្ធ និងអាករដែលជាប់ ។

**ប្រការ ៦.-**

ទំនិញអាចត្រូវបាននាំចេញបណ្ដោះអាសន្នពីដែនគយស្របតាមបញ្ញត្តិប្រការ ១ នៃប្រកាសនេះ សម្រាប់រយៈពេលអតិបរមា ១ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីប្រតិវេទន៍គយនាំចេញ ។ រដ្ឋបាលគយអាចអនុញ្ញាតពន្យាររយៈពេលនេះ នៅពេលមានការស្នើសុំជាលាយលក្ខណ៍អក្សរពីប្រតិវេទករ ។

**ប្រការ ៧.-**

រដ្ឋបាលគយអាចតម្រូវឲ្យមានការតម្កល់និមុត្តិធានា ក្នុងករណីដែលទំនិញនាំចេញបណ្ដោះអាសន្ននោះជាកម្មវត្ថុនៃការជាប់អាករនាំចេញ ។ ក្នុងករណីដែលទំនិញនាំចេញបណ្ដោះអាសន្ននោះជាទំនិញជាប់អាយ័ត ឬទំនិញជាប់កម្រិតកំណត់ ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចឲ្យនាំចេញបណ្ដោះអាសន្ន ទើបរដ្ឋបាលគយអាចតម្រូវឲ្យមានការតម្កល់និមុត្តិធានា ។

**ប្រការ ៨.-**

នៅពេលនាំចូលមកវិញ ប្រតិវេទករត្រូវផ្ដល់សម្អាងគ្រប់គ្រាន់ដល់មន្ត្រីគយមានសមត្ថកិច្ចថា ទំនិញនោះបានធ្វើការនាំចេញបណ្ដោះអាសន្ន រួមមានប្រតិវេទន៍គយនាំចេញ និងឯកសារផ្សេងទៀតដែលបង្ហាញពីតម្លៃបន្ថែមទៅលើទំនិញនោះនៅក្រៅប្រទេស ប្រសិនបើមាន ។

**ប្រការ ៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១០
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ